ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល
# ស្តីពី
# គោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រ
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

# Statement of The Royal Government of Cambodia
# on
# Cambodia’s Marine Fisheries Management
# Key Principles

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០១ អនក**

# សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា
# ស្តីពី
# គោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រ
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

វិស័យជលផលកម្ពុជាមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេស ចំពោះសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការកាត់បន្ថយភាពក្រីក្រ ការបង្កើតការងារ ការធ្វើឱ្យមានសមភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ច តុល្យភាពរូបិយបណ្ណបរទេស និងការការពារបេតិកភណ្ឌធម្មជាតិ។ វិស័យជលផលសមុទ្របានរួមចំណែកក្នុងផលនេសាទសរុបនិងមានការកើនឡើងជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០០៨មក។ ផលនេសាទសមុទ្រសរុបមានប្រមាណជាង១២០ ០០០តោន ក្នុងឆ្នាំ២០១៧ គឺប្រហែល២០ភាគរយនៃផលនេសាទសរុប។ បច្ចុប្បន្ន ផលិតផលជលផលគិតនៅកន្លែងឡើងត្រីមានតម្លៃប្រមាណពី២០០ទៅ៣០០លានដុល្លារក្នុងមួយឆ្នាំ។ តម្លៃផលផលសរុបទូទាំងប្រទេសទាំងទឹកសាប ទាំងទឹកប្រៃបានចូលរួមចំណែកប្រមាណ៧ឬ៨ភាគរយនៃផលិតផលក្នុងស្រុកសរុប។

ទោះបីជាវិស័យជលផលមានសារៈសំខាន់យ៉ាងនេះក៏ដោយ ក៏ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃជលផលសមុទ្រត្រូវបានគំរាមកំហែងដោយបញ្ហាមួយចំនួនរួមមាន ការនេសាទហួសកម្រិតនិងចំនួនទូកនេសាទលើសសមត្ថភាពធៀបនឹងផលចាប់ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានការអនុញ្ញាត ការអភិវឌ្ឍតាមតំបន់ឆ្នេរ និងការបាត់បង់ទីជម្រក។ កត្តាទាំងនេះបណ្តាលឱ្យអ្នកនេសាទខ្នាតតូចនិងគ្រួសាររងគ្រោះដោយផលប៉ះពាល់អវិជ្ជមានពីបញ្ហាទាំងនេះ។ ដើម្បីផលប្រយោជន៍ជាតិវិស័យជលផលសមុទ្រ មានការងារជាច្រើនដែលត្រូវដោះស្រាយក្នុងគោលដៅបង្កើនសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ សេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រនេះត្រូវបានរៀបចំកែលម្អឱ្យបានល្អប្រសើរនូវខ្លឹមសារសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយវិស័យជលផលជាតិឆ្នាំ២០០៥។ សេចក្តីថ្លែងការណ៍ដែលបានរៀបចំឡើងវិញនេះ បានដាក់បញ្ចូលនូវគោលការណ៍និងវិធានការតឹងរ៉ឹងមួយចំនួនថែមទៀតក្នុងការបង្ការ ទប់ស្កាត់និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានការអនុញ្ញាត និងការនេសាទនៅក្នុងនិងក្រៅតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់កម្ពុជា។

**ក- ទស្សនវិស័យ**

ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាពដើម្បីរួមចំណែកដល់ការធានាសន្តិសុខស្បៀងសម្រាប់អនាគតនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននិងភាពចម្រើនរុងរឿងរបស់ប្រទេសជាតិ។

ទស្សនវិស័យនេះទទួលស្គាល់តួនាទីដ៏សំខាន់របស់សកម្មភាពជលផលខ្នាតតូច ដែលមានតួនាទីចម្បងក្នុងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍ សមធម៌ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។

## ខ- គោលការណ៍គន្លឹះនៃការគ្រប់គ្រងជលផលសមុទ្រ

ដើម្បីធានាឱ្យមានប្រសិទ្ធភាព ភាពសក្តិសិទ្ធ និងតម្លាភាពនៃការងារគ្រប់គ្រងផលផលសមុទ្រ ត្រូវផ្អែកលើគោលការណ៍សំខាន់ៗដូចខាងក្រោម៖

**ទី១ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព**: លើកតម្កស់គុល្យភាពរវាងសុខុមាលភាពអេកូឡូស៊ី ដែលនឹងធ្វើឱ្យធនធានជលផលនិងបរិស្ថានមានស្ថានភាពល្អប្រសើរ និងសុខុមាលភាពមនុស្សដែលពាក់ព័ន្ធនឹងការធានាសន្តិសុខស្បៀង បង្កើតមុខរបរការចិញ្ចឹមជីវិត និងប្រាក់ចំណូល។ អាស្រ័យហេតុនេះ ផលប្រយោជន៍ដែលទទួលបានពីជលផលអាចបន្តទុកសម្រាប់មនុស្សជំនាន់ក្រោយ។

**ទី២ អភិក្រមគ្រប់គ្រងផលផលតាមប្រព័ន្ធអេកូឡូស៊ី**: ត្រូវអនុវត្តការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងវិស័យជលផល។

**ទី៣ អភិបាលកិច្ចល្អ**: សម្របសម្រួលការកំណត់ច្បាប់និងបទប្បញ្ញត្តិ មានធនធានគ្រប់គ្រាន់ ការរៀបចំសម្រាប់ការគោរពនិងការអនុវត្តច្បាប់។

**ទី៤ តម្លាភាពនិងការចូលរួម**: លើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការធ្វើផែនការអនុវត្តនិងការគ្រប់គ្រងជលផល។

**ទី៥ អនុម័តគោលការណ៍អនុវត្តល្អរបស់អន្តរជាតិនិងកិច្ចសហការថ្នាក់តំបន់**: ធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង។

**ទី៦ ការសម្រេចចិត្តផ្អែកលើវិទ្យាសាស្ត្រ**: ធានាថាការសម្រេចចិត្តក្នុងការគ្រប់គ្រងជលផលត្រូវបានផ្អែកលើព័ត៌មានវិទ្យាសាស្ត្រដែលល្អបំផុត។

**ទី៧ តុល្យភាពរវាងសមត្ថភាពនេសាទនិងធនធានជលផល**: រក្សាឬស្តារផលស្តុកត្រីទៅតាមកម្រិតសមត្ថភាព ផលិតដើម្បីរក្សាទិន្នផលឱ្យមាននិរន្តរភាពជាអតិបរមា។

**ទី៨ ការគ្រប់គ្រងតាមបែបការបន្សាំ**: គ្របដណ្តប់ការផ្លាស់ប្តូរតាមរយៈការសិក្សានិងការបន្សាំខ្លួន។

**ទី៩ អភិក្រមប្រុងប្រយ័ត្នជាមុន**: មិនពន្យារពេលធ្វើសកម្មភាពដោយសារតែខ្វះព័ត៌មាន និងអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុននៅពេលមានភាពមិនច្បាស់លាស់ ជាពិសេស ភាពមិនច្បាស់លាស់ក្នុងការប៉ាន់ស្មានរបស់កម្រិតសមត្ថភាពផលិតដើម្បីរក្សាទិន្នផលមាននិរន្តរភាពជាអតិបរមា។

## គ- យុទ្ធសាស្ត្រ

### ១- ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃជលផលសមុទ្រ

ដើម្បីឱ្យការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិមាននិរន្តរភាព និងការអនុវត្តគោលការណ៍បរិស្ថានល្អ ផលនេសាទសមុទ្រត្រូវកម្រិតនៅត្រឹម១២០ ០០០តោនក្នុងមួយឆ្នាំ។ ដើម្បីសម្រេចគោលដៅនេះ ចំនួននិងទំហំទូកនេសាទត្រូវកំណត់ឱ្យនៅត្រឹមកម្រិតចំនួនបច្ចុប្បន្ន និងអាចពិចារណាទៅលើការកាត់បន្ថយចំនួននិងទំហំទូកនេសាទនាពេលអនាគតដោយសារការថយចុះធនធានធម្មជាតិ។

**១.១- ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត**

ការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតលើទូកនេសាទកម្ពុជានិងទូកនេសាទបរទេស នៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការគ្រប់គ្រងសមត្ថភាពនេសាទនិងពង្រឹងការតាមដាន ការត្រួតពិនិត្យ និងការអង្កេត ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់។

**១.២- ការគ្រប់គ្រងនាវានេសាទនៅក្នុងដែនសមុទ្រកម្ពុជា**

**ក- ការនេសាទខ្នាតតូច**: គ្រប់គ្រងការនេសាទខ្នាតតូចតាមរយៈការគ្រប់គ្រងនៅក្នុងដែននេសាទ និងសហគ្រប់គ្រងតំបន់គ្រប់គ្រងរួមរបស់សហគមន៍ក្នុងកន្លែងនេសាទសហគមន៍។

**ខ- ការនេសាទខ្នាតមធ្យមនិងខ្នាតធំ**: កំណត់ចំនួនទូកនេសាទខ្នាតមធ្យមនិងខ្នាតធំឱ្យស្ថិតនៅត្រឹមចំនួនទូកបច្ចុប្បន្ន(ឆ្នាំ២០១៨) តាមរយៈប្រព័ន្ធចុះបញ្ជីនិងការផ្តល់លិខិតអនុញ្ញាត និងអាចពិចារណាទៅលើការកាត់បន្ថយចំនួននិងទំហំទូកនេសាទនាពេលអនាគត ដោយសារតោរចយចុះធនធានធម្មជាតិ។

**គ- ការគ្រប់គ្រងនាវានេសាទបរទេស**: ការនេសាទដោយនាវានេសាទបរទេសមិនត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទ នៅក្នុងដែនសមុទ្រកម្ពុជាដែលមិនមែនជាតំបន់មានវិវាទនោះឡើយ។

**១.៣- ការគ្រប់គ្រងនាវាកម្ពុជាដែលពាក់ព័ន្ធនឹងសកម្មភាពនេសាទ(នាវាដឹកជញ្ជូនផលនេសាទនិងនាវាផ្គត់ផ្គង់) កំពុងប្រតិបត្តិការនៅក្នុងដែនសមុទ្រកម្ពុជា**

គ្មានការដឹកជញ្ជូនផល ផលិតផលជលផលណាមួយ ត្រូវបានដឹកជញ្ជូនឬផ្ទេរនៅក្នុងដែនសមុទ្រកម្ពុជាឡើយ លើកលែងតែនាវាដែលមានការអនុញ្ញាតពិសេសសម្រាប់អនុវត្តជាមួយនាវានេសាទខ្នាតតូច។ ការដឹកជញ្ជូនឬផ្ទេរផលផលិតផលជលផលត្រូវមានការអនុញ្ញាតពីសមត្ថកិច្ចជលផល។

**១.៤- ការគ្រប់គ្រងនាវានេសាទនិងនាវាដែលពាក់ព័ន្ធនឹងសកម្មភាពនេសាទកំពុងប្រតិបត្តិការនៅក្នុងសមុទ្រអន្តរជាតិនិងដែនសមុទ្រនៃរដ្ឋដទៃ**

មិនមាននាវានេសាទឬនាវាពាក់ព័ន្ធនឹងការសកម្មភាពនេសាទត្រូវបានអនុញ្ញាតក្នុងការចុះបញ្ជីនិងផ្តល់លិខិតអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅក្នុងដែននេសាទរដ្ឋដទៃឬសមុទ្រអន្តរជាតិឡើយ ដរាបណាដំណើរការចុះបញ្ជីនិងការផ្តល់លិខិតអនុញ្ញាតត្រូវបានរៀបចំឡើងដោយរួមបញ្ចូលទាំងវិធានការត្រួតពិនិត្យនិងអធិការកិច្ចត្រឹមត្រូវទៅតាមច្បាប់។

**១.៥- ការគ្រប់គ្រងជលផលនៅក្នុងតំបន់មានវិវាទ**

ការនេសាទនិងសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្នុងតំបន់មានវិវាទរវាងកម្ពុជានិងប្រទេសជិតខាងត្រូវបានអនុវត្តឱ្យស្របតាមវិធានការគ្រប់គ្រងនិងអភិរក្សរួមគ្នាដែលបានឯកភាព។

## ២- ការគ្រប់គ្រងទីជម្រកសំខាន់ៗ

- រាជរដ្ឋាភិបាលកម្ពុជាក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល គាំទ្រយ៉ាងសកម្មដល់ការស្តារឡើងវិញនូវការបាត់បង់ទីជម្រកតំបន់ឆ្នេរដូចជា ផ្កាថ្ម ព្រៃកោងកាង ឬស្មៅសមុទ្រ ដោយទទួលស្គាល់តួនាទីរបស់វាជាកន្លែងបន្តពូជ ផ្តល់ចំណី ប៉ប៉នសម្រាប់កូនត្រី និងដែនជម្រកសុវត្ថិភាព
- គាំទ្រការគ្រប់គ្រងនិងប្រើប្រាស់តំបន់នានាដូចជា ដែនជម្រកសុវត្ថិភាព ដែនសមុទ្រការពារ តំបន់គ្រប់គ្រងផលផលសមុទ្រ ជាដើម ដើម្បីអភិរក្សនិងការពារទីជម្រកសំខាន់ៗ
- ហាមឃាត់ការនេសាទឬសកម្មភាពទាក់ទងនឹងការនេសាទដែលបង្កឱ្យមានការបំផ្លាញផ្កាថ្មឬស្មៅសមុទ្រដូចជា អួនអូសជាដើម។

## ៣- ទិន្នន័យនិងព័ត៌មានជលផល

- រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពង្រឹងប្រព័ន្ធប្រមូលទិន្នន័យនិងរៀបចំប្រព័ន្ធព័ត៌មានជលផលមូលដ្ឋានដែលមានលក្ខណៈច្បាស់លាស់ដែលអាចជួយដល់ការវាយតម្លៃឱ្យបានកាន់តែប្រសើរអំពីស្ថានភាពធនធានជលផល ក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងគោលនយោបាយការត្រួតពិនិត្យនិងវាយតម្លៃនៅកម្រិតថ្នាក់ជាតិនិងថ្នាក់តំបន់
- ចែករំលែកទិន្នន័យនិងព័ត៌មានសំខាន់ៗជាមួយបណ្តាប្រទេសអាស៊ាននិងតាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋានថ្នាក់ពិភពលោក។

## ៤- ការអភិវឌ្ឍស្ថាប័ននិងហេដ្ឋារចនាសម្ព័ន្ធជលផល

- រាជរដ្ឋាភិបាលកម្ពុជាលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យជលផលសមុទ្រ ដើម្បីធានាបាននូវសេវាដែលមានគុណភាពក្នុងវិស័យជលផលនិងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម
- រាជរដ្ឋាភិបាលកម្ពុជាជំរុញការផ្សព្វផ្សាយជាសាធារណៈនៅតាមសហគមន៍ សាលារៀន និងថ្នាក់ជាតិអំពីសារៈសំខាន់នៃវារីសត្វនិងវារីរុក្ខជាតិចម្រុះនិងការអភិរក្សដើម្បីផលប្រយោជន៍សេដ្ឋកិច្ច សន្តិសុខស្បៀង

និងជីវភាពរស់នៅ។ សារៈសំខាន់នៃទីជម្រកសំខាន់ៗនឹងត្រូវផ្សព្វផ្សាយផងដែរ ដើម្បីធានាថាច្បាប់និងបទប្បញ្ញត្តិនានាត្រូវបានយល់ដឹងនិងអនុវត្តតាម

- រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ពីសារៈសំខាន់នៃការងារស្រាវជ្រាវសមុទ្រ ដើម្បីជាមូលដ្ឋានវិទ្យាសាស្ត្រដល់អ្នកធ្វើគោលនយោបាយនិងបង្កើនការគាំទ្រក្នុងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពមន្ត្រីស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍជលផលសមុទ្រ និងមជ្ឈមណ្ឌលអភិរក្សជលផលសមុទ្រ។

## ៥- ថវិកានិងហេដ្ឋារចនាសម្ព័ន្ធជលផល

- រាជរដ្ឋាភិបាលកម្ពុជាលើកកម្ពស់ការវិនិយោគឯកជននៅក្នុងវិស័យជលផលសមុទ្រនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកែច្នៃផល ផលិតផលជលផលដើម្បីបង្កើនការប្រកួតប្រជែងទីផ្សារជលផល
- រាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពផងដែរ ក្នុងការប្រើប្រាស់ប្រាក់ចំណូលជលផលដើម្បីផ្តល់ហិរញ្ញប្បទានដល់ការកែទម្រង់ ការងារស្រាវជ្រាវ ការតាមដាន ការត្រួតពិនិត្យ និងការអង្កេត សំដៅបង្កើនធនធានជលផលសម្រាប់ការកែលម្អជីវភាពរស់នៅ
- ព្រះរាជាណាចក្រកម្ពុជាប្តេជ្ញាអនុវត្តអនុសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិ ព្រមទាំងបទប្បញ្ញត្តិនានាជាពិសេស ការអនុវត្តកិច្ចព្រមព្រៀងរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។ ក្រៅពីនេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងពិនិត្យនិងពិភាក្សាតាមនីតិវិធីលើការចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីផលស្តុកត្រីរបស់អង្គការសហប្រជាជាតិ និងកំពុងពិចារណាលើការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រផងដែរ។

**ព្រះរាជាណាចក្រកម្ពុជាបន្តធ្វើការជាមួយអង្គការអន្តររដ្ឋាភិបាលក្នុងតំបន់និងពិភពលោកដូចជា៖**

- **អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ:** ក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល និងគោលការណ៍ស្ម័គ្រចិត្តសម្រាប់និរន្តរភាពការនេសាទខ្នាតតូចនៅក្នុងបរិបទសុវត្ថិភាពស្បៀង និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងផែនការសកម្មភាពអន្តរជាតិនានា
- **មជ្ឈមណ្ឌលអភិវឌ្ឍន៍វិស័យជលផលនៅតំបន់អាស៊ីអាគ្នេយ៍:** ផែនការសកម្មភាពដើម្បីនិរន្តរភាពវិស័យជលផលសម្រាប់ធានាសន្តិសុខស្បៀងនៅតំបន់អាស៊ាន ឆ្ពោះទៅកាន់ឆ្នាំ២០២០ និងឆ្ពោះទៅកាន់ឆ្នាំ២០៣០
- លេខាធិការដ្ឋានទទួលបន្ទុកផែនការសកម្មភាពថ្នាក់តំបន់ ដើម្បីលើកកម្ពស់ការនេសាទប្រកបដោយភាពទទួលខុសត្រូវរួមទាំងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត
- គណៈកម្មការជលផលអាស៊ីប៉ាស៊ីហ្វិក។

គោលការណ៍គន្លឹះខាងលើនេះ នឹងក្លាយជាឯកសារក្របខ័ណ្ឌគោលនយោបាយគ្រប់គ្រងជលផលសមុទ្រជាតិ និងជាត្រីវិស័យក្នុងការរៀបចំផែនការសកម្មភាពជាតិនានាដែលទាក់ទងនឹងវិស័យជលផលសមុទ្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ សៅរ៍ ១៤ កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**KINGDOM OF CAMBODIA**
**Nation Religion King**

ROYAL GOVERNMENT OF CAMBODIA
No: 01 Sor Thor Kor

# STATEMENT OF THE ROYAL GOVERNMENT OF CAMBODIA
# ON
# CAMBODIA'S MARINE FISHERIES MANAGEMENT KEY PRINCIPLES

The Cambodian Fisheries sector is considerable importance to the national development objectives, especially to food and nutrition security; poverty reduction; employment; equity and economic efficiency; foreign exchange balance and the protection of natural heritage. The marine fisheries sector has contributed to the total fish catch production and has been increasing every year since 2008. The total marine production was over 120,000 tonnes in 2017, accounting for about 20% of the total fish catch production. Currently, the fisheries production values around US$ 200-300 million per year at the point of landing. The total value of fisheries across the country, both freshwater and marine water contributes about 7-8% of GDP.

However, despite this importance, the sustainable development of marine fisheries is threatened by a number of issues that include overfishing and overcapacity of the fishing fleet; illegal, unreported and unregulated (IUU) fishing; coastal development; and habitat degradation. The small-scale fishers and their families are particularly vulnerable to the adverse impacts of these issues. It is in the national interest to address the issues to increase food security, reduce poverty and improve livelihoods of the people. The Statement of the Royal Government on Marine Fisheries Management Key Principles is prepared to improve the statement of the Royal Government on National Fisheries Policy 2005. The marine fisheries statement incorporates a number of more stringent principles and measures to prevent, deter, and eliminate illegal, unreported and unregulated fishing, and fishing in and outside the Cambodia's exclusive economic zone.

## A .VISION

The management, conservation and development of sustainable fisheries resources that contribute to ensuring future food security, socioeconomic development, and people's livelihoods enhancement and the nation's prosperity.

This vision recognizes the important role of small-scale fisheries in improving food security and nutrition, poverty eradication, development, equity and sustainable resource utilization.

## B. KEY PRINCIPLES OF MARINE FISHERIES MANAGEMENT

To ensure the effectiveness, efficiency and transparency of marine fisheries management, the following key principles shall be enforced:

1) **Sustainable development**: To promote a balance between ecological well-being that focuses on healthy fisheries resources and environment, and human well-being that pertains to food security, employment, livelihoods and income. So that the benefits derived from the fisheries are available for future generations;
2) **Ecosystem approach to fisheries management:** To implement sustainable development in the fisheries sector;
3) **Good governance:** To facilitate the setting of rules and regulations, adequate resources and arrangements for compliance and enforcement;
4) **Transparency and participation:** To encourage the participation of all stakeholders in both fisheries planning and management;
5) Adoption of international best practice and regional cooperation: To cooperate strongly with neighboring countries;
6) **Science-based decision-making:** To ensure the fisheries management decisions are based on the best available scientific information;
7) **Balance between fishing capacity and fisheries resources:** To maintain or restore fish stocks to a level capable of producing the maximum sustainable yield (MSY);
8) **Adaptive management:** To embrace change through learning and adapting; and
9) **Precautionary approach:** To do not delay action because of lack of information and applies the precautionary approach when uncertainty exists particularly uncertainty in the MSY estimate.

## C. STRATEGIES

### 1. SUSTAINABLE DEVELOPMENT OF MARINE FISHERIES

In order to ensure sustainable management and conservation of natural resources and applying sound environmental principles, the marine catch will be maintained at 120,000 tonnes/year. To achieve this target, the size and structure of the fishing vessels will be frozen at current levels and may be considered to decline size and structure of the fleet in the future in accordance with the decrease of natural resources.

### 1.1 Illegal, Unreported and Unregulated (IUU) fishing

Prevent, deter and eliminate IUU fishing of both Cambodian and foreign fishing vessels that are operating in Cambodian marine waters through the management of fishing capacity and strengthening of monitoring, control and surveillance (MCS), and increased regional cooperation.

### 1.2 Fishing vessels management in Cambodian marine waters

a) Small-scale fishing: Manage small-scale fishing through management in fishery domains and co-management of community fisheries management areas.
b) Medium-scale and large-scale fishing: Limit medium-scale and large-scale fishing vessels at current levels (2018) through a system of registration, licensing and may be considered to decline size and structure of the fishing vessels in the future in accordance with the decrease of natural resources.
c) Management of foreign fishing vessels: there will be no authorization of foreign fishing vessels to fish in Cambodian non-disputed marine waters.

### 1.3 Management of Cambodian fishing and fishing related vessels (fish carriers and support vessels) operating in Cambodian marine waters

No transportation of fish and fishery products shall be made or transshipped in the Cambodian marine waters, except by special authorization for small-scale operations. The transportation or transshipment of fish and fishery products shall be authorized by the competent fisheries officials.

### 1.4 Management of Cambodian fishing and fishing related vessels operating in the high seas and foreign marine waters

No fishing or fishing related vessels or vessels will be registered or licensed to either fish or carry out fishing-related activities in the high seas or foreign marine waters until an approved registration and licensing process and register is developed that includes adequate control and inspection measures in accordance with legislations.

### 1.5 Fisheries management in disputed overlap areas

Fishing and fishing-related activities in disputed overlap areas between Cambodia and neighboring countries should be carried out in accordance with joint conservation and management measures agreed by respective countries.

## 2. MANAGEMENT OF CRITICAL HABITATS

- The Royal Government of Cambodia, in partnership with Non-Governmental Organizations, actively supports the restoration of degraded coastal habitats of coral reefs, mangroves and sea-grass beds in recognition of the role they play as fish breeding, feeding, nurseries for fish seed and refuge sites;
- The support of management and utilization of Refugia, Marine Protected Areas and Marine Fisheries Management Areas is to conserve and protect critical habitats;
- The prohibition of any fishing or fishing-related activity that may cause the destruction of sea-grass or coral reefs, such as trawling.

## 3. FISHERIES DATA AND INFORMATION

- Fisheries Administration of the Ministry of Agriculture, Forestry and Fisheries shall strengthen its existing data collection systems and develop Database System that would support better assessment of the status of the fisheries resources, policy decision making, monitoring and evaluation at both the national and regional levels;
- The important data and information will be shared within ASEAN Member States and through global fisheries databases.

## 4. DEVELOPMENT OF FISHERIES INSTITUTIONS AND THEIR INFRASTRUCTURE

- The Royal Government of Cambodia promotes human resources development within the marine fisheries sector to ensure quality service within fisheries in order to improve socioeconomic development;
- The Royal Government of Cambodia promotes public awareness raising in communities, nationally and in schools, of the importance of aquatic biodiversity and its conservation for the benefit of the economy, food security and livelihoods. Awareness of the importance of critical habitats will also be raised to ensure that the regulations governing them are understood and followed;
- The Royal Government of Cambodia recognizes the importance of marine research for informing decision making and will provide increased support to strengthen the infrastructure

and staff capacity of Marine Fisheries Research and Development Institute and Marine Fisheries Conservation Centre.

**5. BUDGET AND FISHERIES INFRASTRUCTURE**

- The Royal Government of Cambodia promotes private investment in the marine fisheries sector and development of post-harvest infrastructure to increase the competitive market position of the fisheries;
- The Royal Government of Cambodia also provides priority to use fishery revenues to finance reforms, research, and MCS to increase resources for livelihood improvement;
- The Kingdom of Cambodia commits to implement international conventions, agreements, and instruments, in particular the implementation of the FAO Port States Measures Agreement (PSMA) that Cambodia already ratified. Beside this, the Royal Government of Cambodia is reviewing and discussing the procedure to access in becoming a member of the UN Fish Stocks Agreement (UNFSA), and is considering its ratification of the UN Convention on the Law of the Sea (UNCLOS).

The Royal Government of Cambodia will also continue to work with global and regional inter-governmental organizations as follows:

- The Food and Agriculture Organization of the UN (FAO): Code of Conduct for Responsible Fisheries (CCFR), Voluntary Guidelines for Securing Sustainable Small-scale Fisheries in the Context of Food Security and Poverty Alleviation (VG SSF), and International Plans of Action (IPOAs);
- The Southeast Asian Fisheries Development Centre (SEADEC): Resolution and Plan of Action on Sustainable Fisheries for Food Security for the ASEAN Region Towards 2020 and 2030 (Res/POA));
- The Secretariat of Regional Plan of Action to promote responsible fishing practices including combating illegal, unreported, and unregulated (IUU) fishing in the Region (RPOA-IUU); and
- The Asia Pacific Fisheries Commission (APFIC).

The aforementioned key principles will become a National Marine Fisheries Management Policy Framework and a guide for developing National Plan of Actions pertaining to Marine Fisheries of Cambodia.

Phnom Penh, 12th October 2019
**Prime Minister**

Samdech Akka Moha Sena Padei Techo **Hun Sen**

រៀបចំបោះពុម្ពដោយ ៖
រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការបោះពុម្ពផ្សាយនេះ ត្រូវបានផលិតឡើង ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ខ្លឹមសារជាការទទួលខុសត្រូវតែមួយគត់របស់រដ្ឋបាលជលផលហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបទេ។